ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តស្ទៀមរាប

ក្រុងស្ទៀមរាប

សង្កាត់ស្រែថ្មី

លេខ ០៣..ស.ង..ដ.ក

ដីកា
ស្តីពី
ការលើកទឹកចិត្តសហគ្រិនភាពវ័យក្មេង

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- យោងអនុក្រឹត្យលេខ ២២ អនុក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងការៈកិច្ចទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ។
- យោងស្មារតីអង្គប្រជុំសាមញ្ញប្រចាំខែរបស់ក្រុមប្រឹក្សាសង្កាត់ស្រែថ្មីលើកទី៥៣ ថ្ងៃទី១០ ខែ...ធ្នូ..... ឆ្នាំ២០២១ និងយោងតាមការពិភាក្សាដើម្បីសម្រេចលើ ដីកា ស្តីពី ការលើកទឹកចិត្តដល់សហគ្រិនភាពវ័យក្មេង ក្នុងសង្កាត់ស្រែថ្មី។

ដោយមើលឃើញពីការប្រឈមរបស់សហគ្រិនភាពវ័យក្មេងដែលកំពុងប្រកបអាជីវកម្មដូចនេះ ក្រុមប្រឹក្សាសង្កាត់ស្រែថ្មី

សម្រេច

ប្រការ១._ដីកានេះមានគោលបំណង លើកកម្ពស់អាជីវកម្មរបស់សហគ្រិនភាពវ័យក្មេង និងផ្តល់ឱកាស ដល់យុវជនខ្មែរទាំងពីរភេទបានចូលរួមយ៉ាងសកម្មនៅក្នុងការប្រកបអាជីវកម្ម តាមគោលគំនិត និងក្តីស្រមៃរបស់ខ្លួន។

ប្រការ២._ដីកានេះមានវិសាលភាពអនុវត្តតែនៅក្នុងដែនដី នៃសង្កាត់ស្រែថ្មី។

ប្រការ៣._រដ្ឋបាលសង្កាត់ផ្តល់ឱកាស និង លើកទឹកចិត្តឱ្យក្រុមយុវជនចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាសង្កាត់ ។

ប្រការ៤._ថែរក្សា និង រៀបចំសណ្តាប់ធ្នាប់សាធារណៈអោយបានល្អ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការប្រកបអាជីវកម្មរបស់យុវជន និងប្រជាពលរដ្ឋ ។

ប្រការ៥._ទប់ស្កាត់អំពើចោរកម្ម អំពើហិង្សាក៏ដូចជាសកម្មភាពក្មេងទំនើងនានានៅក្នុងសង្កាត់ ដើម្បីបង្កឱកាសដល់យុវជនក្នុងការប្រកបអាជីវកម្ម ។

Scanned with CamScanner

ប្រការ៦._រដ្ឋបាលសង្កាត់នឹងស្វែងរកកិច្ចសហការខូលំខូលាយ ជាមួយអ្នកពាក់ព័ន្ធរួមទាំងអង្គការនានា ជាពិសេសសហគ្រិន ឬអាជីវករនានាដែលទទួលបានជោគជ័យឱ្យចែករំលែកបទពិសោធន៍ និង ផ្តល់ការបណ្តុះបណ្តាលដល់សហគ្រិនវ័យក្មេងនៅក្នុងសង្កាត់ ។

ប្រការ៧._បញ្ចូលផែនការការលើកទឹកចិត្តសហគ្រិនភាពវ័យក្មេង ទៅក្នុងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល របស់សង្កាត់ ។

ប្រការ៨._ស្វែងរកដៃគូរអភិវឌ្ឍន៍ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលពីអាជីវកម្មនិងផ្តល់ប្រាក់កម្ចីសម្រាប់យុវជនដែលមានបំណងចង់បង្កើត និងកំពុងដំណើរការអាជីវកម្មរបស់ខ្លួនដែលមានបំណងស្នើសុំថវិកាដើម្បីប្រកបអាជីវកម្មខ្នាតតូច និងមធ្យមដោយមានការប្រាក់ទាប។ នីតិវិធីនៃការដាក់សំណើសុំខ្ចីថវិកា ត្រូវកំណត់នៅក្នុងគោលការណ៍ណែនាំរបស់សង្កាត់។

ប្រការ៩._រដ្ឋបាលសង្កាត់នឹងចែករំលែកព័ត៌មានពាក់ព័ន្ធអំពីអាជីវកម្ម និងឱកាសសម្រាប់បង្កើតអាជីវកម្ម ដល់ប្រជាពលរដ្ឋក្នុងសង្កាត់ ជាពិសេសសហគ្រិនភាពវ័យក្មេង។

ប្រការ១០._ក្រុមប្រឹក្សាសង្កាត់នឹងជួយសម្រួលរាល់ឯកសារដែលទាក់ទងទៅនឹងការប្រកបអាជីវកម្មជាមួយនឹងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ។

ប្រការ១១._ដីការនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ.....ខែ.....ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ស្រង៉ែ ថ្ងៃទី១៣ ខែ.....ឆ្នាំ២០២១

ចៅសង្កាត់

ចម្លងជូន៖
- រដ្ឋបាលក្រុងសៀមរាប
- ការិយាល័យកិច្ចការនារីក្រុងសៀមរាប
  "ដើម្បីគោរពជូនជ្រាប"
- មេភូមិគ្រប់ភូមិ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Scanned with CamScanner